# សុន្ទរកថា

## សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
## ប្រធានគណៈកម្មាធិការជាតិជំរឿនទូទៅប្រជាជន
## នៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩

## ថ្លែងនៅក្នុងពិធីប្រកាសតួលេខបណ្ដោះអាសន្ននៃ
## ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩

សណ្ឋាគារភ្នំពេញ,ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩

- ឯកឧត្ដមកិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ អនុប្រធានគណៈកម្មាធិការជាតិជំរឿន និងជាប្រធានគណៈកម្មការបច្ចេកទេសជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩
- ឯកឧត្ដម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំ មន្ត្រីរាជការនៃក្រសួងផែនការ
- ឯកឧត្ដម លោកជំទាវ លោក លោកស្រី តំណាងដៃគូអភិវឌ្ឍន៍ ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ
- សមាជិក សមាជិកានៃអង្គពិធី ទាំងអស់ជាទីមេត្រី!

១. ថ្ងៃនេះ ខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ និងមានក្ដីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានមកចូលរួមជាអធិបតី ក្នុងពិធីប្រកាសតួលេខបណ្ដោះអាសន្ននៃជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា នៅខែមីនា ឆ្នាំ២០១៩ ដែលបានប្រព្រឹត្តទៅប្រកបដោយជោគជ័យ ដោយមានការចូលរួមសហការពីគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ បានទទួលលទ្ធផលយ៉ាងសមស្របបំផុត។

២. ក្នុងនាមគណៈកម្មាធិការជាតិជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើរដោយស្មោះ ចំពោះការខិតខំប្រឹងប្រែងបំពេញការងារក្នុងស្មារតីសហការ និងទទួលខុសត្រូវខ្ពស់របស់មន្ត្រីជំរឿនគ្រប់ថ្នាក់ តាំងពីសមាជិកសមាជិកានៃគណៈកម្មាធិការជំរឿនគ្រប់ថ្នាក់ រហូតដល់អាជ្ញាធរថ្នាក់ស្រុក ឃុំ ភូមិ និងមន្ត្រីនគរបាលដែលបានចូលរួមចំណែកដោយប្រសិទ្ធភាព បំពេញភារកិច្ចយ៉ាងសកម្មជាមន្ត្រីសម្ភាសន៍ មន្ត្រីត្រួតពិនិត្យក្នុងប្រតិបត្តិការជំរឿន ហើយទន្ទឹមនេះក៏សូមអបអរ ចំពោះការគាំទ្រដ៏ស្មោះស្ម័គ្ររបស់មន្ត្រីរាជការគ្រប់ក្រសួង ស្ថាប័នជាតិ និងបងប្អូនជនរួមជាតិនៅគ្រប់ទីកន្លែងក្នុងទូទាំងប្រទេស។



Scanned with CamScanner

៣. ខ្ញុំសូមសំដែងនូវការដឹងគុណ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានអនុញ្ញាតឲ្យប្រើប្រាស់ថវិកាជាតិ សម្រាប់អនុវត្តការងារជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ ដែលជាការងារសំខាន់ជាប្រវត្តិសាស្ត្ររបស់កម្ពុជា ដើម្បីអភិវឌ្ឍកម្ពុជា។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ចំពោះមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) ដែលបានគាំទ្រទាំងផ្នែកបច្ចេកទេស ថវិកា និងបានផ្តល់ជំនួយលើបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា(ICT) ។ សូមអរគុណសហគមន៍អឺរ៉ុប អង្គការ Sida ទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) បានផ្តល់ជំនួយទីប្រឹក្សាបច្ចេកទេសជំរឿនរយៈពេលវែង និងសាធារណរដ្ឋប្រជាមានិតចិន បានផ្តល់ជំនួយសម្ភារៈបរិក្ខារជំរឿន រួមមានមធ្យោបាយដឹកជញ្ជូន (រថយន្ត និងម៉ូតូ) កុំព្យូទ័រ ម៉ាស៊ីនថតចម្លង ជាដើម។

៤. ដូចឯកឧត្តម លោកជំទាវ លោក លោកស្រី បានជ្រាបហើយថា ជំរឿនប្រជាជនគឺជាប្រភពយ៉ាងសំខាន់នៃទិន្នន័យថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ រហូតដល់កម្រិតថ្នាក់តូចបំផុត ដូចជាមណ្ឌលជំរឿន។ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ គឺជាជំរឿនលើកទី ៤ នៅក្នុងការធ្វើជំរឿនជាបន្តបន្ទាប់នៅព្រះរាជាណាចក្រកម្ពុជា តាំងពីឆ្នាំ១៩៦២ ឆ្នាំ១៩៩៨ និងឆ្នាំ២០០៨ និងសូមថ្លែងអំណរគុណផងដែរនូវការសហការពីមន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យ ព្រមទាំងមន្ត្រីទាំងអស់ដែលបានចូលរួមក្នុងការងារជំរឿនរួមទាំងមន្ត្រីថ្នាក់កណ្តាល មន្ត្រីថ្នាក់រាជធានី ខេត្ត និងការសហការពីប្រជាជនកម្ពុជាផ្ទាល់តែម្តង។

៥. ជំរឿនប្រជាជនរបស់ប្រទេសកម្ពុជា ឆ្នាំ២០១៩ នឹងផ្តល់នូវទិន្នន័យច្បាស់លាស់អំពីទំហំប្រជាជន និងចរិតលក្ខណៈប្រជាជន បន្ទាប់ពីជំរឿនប្រជាជន ឆ្នាំ២០០៨។ ទិន្នន័យទាំងអស់នេះមានសារៈសំខាន់ណាស់ សម្រាប់រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ និងអ្នកប្រើប្រាស់ទាំងឡាយ ធ្វើសេចក្តីសម្រេចប្រកបដោយប្រសិទ្ធភាព ក្នុងការកសាងផែនការឆ្ពោះទៅរកការអភិវឌ្ឍជាតិប្រកបដោយចីរភាព។ គោលនយោបាយជាតិប្រជាជន គឺជាលទ្ធផលសំខាន់មួយ ដែលទទួលបានពីការធ្វើជំរឿនប្រជាជន ឆ្នាំ២០១៩ ផងដែរ។ ការធ្វើចំណោលប្រជាជនដោយផ្អែកលើទិន្នន័យជំរឿនក៏ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ ដោយរាជរដ្ឋាភិបាល ក្រសួងផែនការ និងបណ្តាក្រសួងផ្សេងៗ។ ជាការពិតណាស់ គ្រប់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា អង្គការមិនមែនរដ្ឋាភិបាល ភ្នាក់ងារអន្តរជាតិ និងបណ្តាអ្នកស្រាវជ្រាវ មានជំនឿទុកចិត្តលើទិន្នន័យជំរឿន និងទទួលស្គាល់ថាជាស្ថិតិផ្លូវការថ្នាក់ជាតិ។

៦. ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាលើកទីបួន ដែលបានអនុវត្តនៅឆ្នាំ២០១៩ មានរយៈពេលដប់មួយឆ្នាំ បន្ទាប់ពីជំរឿនលើកទីបី នៅឆ្នាំ២០០៨។ ជំរឿននឹងផ្តល់នូវ



Scanned with CamScanner

ទិន្នន័យប្រជាជនទាន់សម័យកាល ដែលជាមូលដ្ឋានសម្រាប់តាមដានដំណើរការនៃកិច្ចអភិវឌ្ឍន៍ ការវាយតម្លៃ និងការរៀបចំគោលនយោបាយផ្សេងៗ ដែលជាតម្រូវការរបស់រាជរដ្ឋាភិបាលកម្ពុជា។ ទិន្នន័យនេះមានតម្លៃណាស់សម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ព្រមទាំងកម្មវិធីអភិវឌ្ឍន៍ដទៃទៀត និងការសហការជាមួយប្រព័ន្ធស្ថិតិអន្តរជាតិ។ ការរៀបចំដំណើរការជំរឿនគ្រប់ដំណាក់កាល បានរៀបចំដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី !**

៧. ដូចប្រសាសន៍របស់ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ បានបញ្ជាក់ជូនមកហើយថា ការងារជំរឿនប្រជាជនជាការងារជាតិដ៏ធំធេងមានសារៈសំខាន់បំផុត និងមានចរិតប្រវត្តិសាស្ត្រ។ នៅពាក់កណ្តាលឆ្នាំ ២០២០ ការងារនេះនឹងនាំមកនូវព័ត៌មានអំពីចំនួនប្រជាជន និងចរិតលក្ខណៈប្រជាជនសំខាន់ៗជាលម្អិត តាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់ភូមិដែលជាកម្រិតភូមិសាស្ត្រតូចបំផុតនៅព្រះរាជាណាចក្រកម្ពុជាយើង។ ការងារជំរឿនប្រជាជន ជាការងារដែលអ្នកប្រើប្រាស់ទិន្នន័យស្ថិតិទាំងឡាយត្រូវការចាំបាច់ សម្រាប់រៀបចំជាគោលនយោបាយ កម្មវិធីសកម្មភាពនានា ការគ្រប់គ្រងរដ្ឋបាល ព្រមទាំងការធ្វើសេចក្តីសម្រេចនានា សមស្របតាមការពិតជាក់ស្តែងរបស់ប្រទេស។

៨. ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ បានរាយការណ៍រួចមកហើយថា ការរៀបចំការងារជំរឿនប្រជាជន ប្រតិបត្តិការតាមមូលដ្ឋាន ការកែច្នៃទិន្នន័យ មកដល់ពេលនេះ គឺប្រព្រឹត្តទៅបានល្អប្រសើរ និងរលូនតាមផែនការជំរឿន។ ជាទូទៅ ជំរឿនប្រជាជនអាចផ្តល់នូវការឆ្លុះបញ្ចាំងអំពីស្ថានភាពប្រជាជនរបស់ប្រទេស និងជួយដល់រាជរដ្ឋាភិបាលក្នុងការរៀបចំតាក់តែងគោលនយោបាយបានជាក់លាក់ និងគម្រោងកម្មវិធីផ្សេងៗ ដើម្បីទទួលបាននូវតុល្យភាពរវាងប្រជាជន និងកិច្ចអភិវឌ្ឍន៍ ។ ជំរឿនប្រជាជន គឺជាប្រភពព័ត៌មានតែមួយគត់អំពីចំនួន និងចរិតលក្ខណៈប្រជាជន។ ជំរឿនមានវិសាលភាពរឹងមាំល្អិតល្អន់ និងផ្តល់ឲ្យចំនួនប្រជាជនក្នុងតំបន់រហូតដល់ថ្នាក់ក្រុមតូចៗថែមទៀត ដែលជាតម្រូវការមួយដែលប្រភពទិន្នន័យផ្សេងៗទៀតមិនមានឡើយ។ ជំរឿនក៏ផ្តល់ជូនផងដែរនូវក្របខ័ណ្ឌសំណាកជ្រើសរើសគំរូ ក៏ដូចជាចំណុចផ្តើមនៃចំនួនប្រជាជនដែលទាក់ទងនឹងការធ្វើចំណោល ឬព្យាករណ៍ចំនួនប្រជាជន ដែលជាកត្តាសំខាន់សម្រាប់ធ្វើផែនការតាមវិស័យ។ លើសពីនេះទៀត ជំរឿនបានអនុវត្តតាមនិយមន័យ និងចំណាត់ថ្នាក់អន្តរជាតិ ដូច្នេះទិន្នន័យជំរឿនអាចផ្តល់នូវការប្រៀបធៀបសូចនាករ ដែលជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍក្នុងចំណោមបណ្តាប្រទេសនានា។



Scanned with CamScanner

៩. ក្នុងពេលនេះ ខ្ញុំនឹងប្រកាសផ្សាយតួលេខបណ្ដោះអាសន្ននៃចំនួនគ្រួសារ ចំនួនប្រជាជន តាមភេទ ខេត្ត ក្រុង និងដង់ស៊ីតេប្រជាជន ដែលអាចប្រើប្រាស់បានជាបណ្ដើរៗរហូតដល់ការប្រកាសជាផ្លូវការនូវលទ្ធផលចុងក្រោយ នៃការធ្វើជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ដែលគ្រោងនឹងធ្វើនៅត្រីមាសទីពីរឆ្នាំ២០២០ ខាងមុខ។

១០. តាមតួលេខបណ្ដោះអាសន្នក្នុងទូទាំងប្រទេសកម្ពុជា គិតត្រឹមថ្ងៃទី ០៣ ខែមីនា ឆ្នាំ ២០១៩ ប្រជាជនសរុប តាមវិធីសាស្ត្រឃើញរាប់ (de-facto) មានចំនួន ១៥.២៨៨.៤៨៩ នាក់ ក្នុងនោះមានប្រុស ៧.៤១៨.៥៧៧ នាក់ និងស្រី ៧.៨៦៩.៩១២ នាក់។ តាមតួលេខបណ្ដោះអាសន្ននេះ យើងពិនិត្យឃើញថាចំនួនប្រជាជនកម្រិតថ្នាក់ជាតិមាននិន្នាការកើនឡើងយឺត ដោយសារអត្រាផ្ដល់កំណើត និងអត្រាកំណើនប្រជាជនបានថយចុះស្របតាមការព្យាករណ៍ដែលបានរំពឹងទុក។ អត្រាកំណើនប្រជាជនប្រចាំឆ្នាំបានថយចុះ ពី ១,៥ ភាគរយ ក្នុងចន្លោះឆ្នាំ១៩៩៨ និង ២០០៨ មក ១,២ ភាគរយ ក្នុងចន្លោះឆ្នាំ២០០៨ និង ២០១៩។ អត្រាកំណើនប្រចាំឆ្នាំរបស់កម្ពុជាក្នុងទសវត្សចុងក្រោយនេះ យើងពិនិត្យឃើញថា ខ្ពស់ជាងអត្រាកំណើនមធ្យមនៅអាស៊ីអាគ្នេយ៍ដែលមានតែ ១.០ ភាគរយ។ រាជធានី ខេត្តដែលមានចំនួនប្រជាជនច្រើនជាងគេបំផុត គឺភ្នំពេញមាន ២.១២៩.៣៧១ នាក់ ហើយខេត្តកែបមានប្រជាជនតិចជាងគេបំផុត ៤១.៧៩៨ នាក់ ប៉ុណ្ណោះ។ ទំហំគ្រួសារជាមធ្យមមាន ៤.៦ សម្រាប់ទូទាំងប្រទេស ហើយសូចនាករសំខាន់មួយដែលត្រូវយកចិត្តទុកដាក់ គឺដង់ស៊ីតេប្រជាជន ពោលគឺចំនួនប្រជាជនក្នុងផ្ទៃដីមួយគីឡូម៉ែត្រការ៉េ។ ដង់ស៊ីតេប្រជាជនស្មើនឹង ៨៦ នាក់ ក្នុងផ្ទៃដីមួយគីឡូម៉ែត្រការ៉េ នៅឆ្នាំ២០១៩។ អត្រាភេទ គឺជាចំនួនបុរសក្នុងចំណោមស្ត្រី ១០០ នាក់។ អត្រាភេទ តាមតួលេខបណ្ដោះអាសន្ននៃជំរឿនប្រជាជន ឆ្នាំ២០១៩ មានបុរស ៩៤ នាក់ ក្នុងចំណោមស្ត្រី ១០០ នាក់ ដោយមិនមានការប្រែប្រួលបើប្រៀបធៀបនឹងឆ្នាំ ២០០៨។

១១. បើពិនិត្យតាមតំបន់ភូមិសាស្ត្រនៃប្រទេស តួលេខបណ្ដោះអាសន្ននៃជំរឿនប្រជាជន ឆ្នាំ២០១៩ បានបង្ហាញថា ប្រជាជនប្រមាណ ៤៨,៩ ភាគរយនៃប្រជាជនទាំងអស់ រស់នៅតំបន់ទំនាបកណ្ដាល ដោយសារតំបន់នេះប្រមូលផ្ដុំដោយខេត្តធំៗដែលមានការអភិវឌ្ឍខ្ពស់។ បន្ទាប់មក តំបន់ទន្លេសាបមានប្រជាជនប្រមាណ ៣១,៤ ភាគរយនៃប្រជាជនទាំងអស់ តំបន់ខ្ពង់រាប និងភ្នំមាន ១២,៧ ភាគរយ និងតំបន់ឆ្នេរ និងសមុទ្រមាន ៦,៩ ភាគរយ។ ការសិក្សាលម្អិតអំពីការប្រមូលផ្ដុំរបស់ប្រជាជននៅទីប្រជុំជន និងជនបទអាចធ្វើទៅបាន បន្ទាប់ពីមានតួលេខចុងក្រោយរបស់ជំរឿន ក៏ដូចជាទិន្នន័យអំពីការបែងចែកតាមអាយុ អក្ខរភាព និងការអប់រំ ការធ្វើអន្តោប្រវេសន៍ និងសកម្មភាពសេដ្ឋកិច្ចរបស់ប្រជាជន។

១២. ដូចខ្ញុំបានបញ្ជាក់រួចមកហើយថា ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ នេះ មានសារៈសំខាន់ធំធេងណាស់។ ជំរឿនគឺជាការងារដ៏ធ្ងន់ធ្ងរដែលត្រូវអនុវត្ត ដោយមាន



Scanned with CamScanner

ការឧត្តម្ភទាំងផ្នែកបច្ចេកទេស ទាំងផ្នែកថវិកា ពីគ្រប់បណ្តាផ្នែកពាក់ព័ន្ធ។ នេះគឺជាការងារសំខាន់បំផុតដែលត្រូវមានគុណភាព និងអាចជឿទុកចិត្តបាន។

១៣. ខ្ញុំមានការសប្បាយរីករាយដោយឃើញថា ការរៀបចំជំហានត្រៀម ការប្រតិបត្តិការតាមមូលដ្ឋាន និងការកែច្នៃទិន្នន័យនៃការងារជំរឿន ឆ្នាំ២០១៩ នេះ បានប្រព្រឹត្តទៅល្អប្រសើរ។ ខ្ញុំសូមអំពាវនាវដល់មន្ត្រីទាំងអស់ ដែលពាក់ព័ន្ធក្នុងការអនុវត្តសកម្មភាពទាំងអស់នៃការធ្វើជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ សូមយកចិត្តទុកដាក់អនុវត្តការងារ ដើម្បីទទួលបានជោគជ័យក្នុងការកែច្នៃទិន្នន័យនៃការធ្វើជំរឿន ការវិភាគ និងការផ្សព្វផ្សាយទិន្នន័យជំរឿនបានទាន់ពេលវេលា ។

១៤. ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណ ចំពោះវត្តមាន ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ដែលបានអញ្ជើញមកចូលរួមយ៉ាងកុះករក្នុងឱកាសប្រកាសតួលេខបណ្តោះអាសន្ន នៃជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ ដោយទឹកចិត្តសោមនស្សរីករាយ ដែលញ៉ាំងឲ្យពិធីនេះប្រព្រឹត្តទៅប្រកបដោយបរិយាកាសស្និទ្ធស្នាល និងអធិកអធមក្រៃលែង។

១៥. ជាទីបញ្ចប់ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ តំណាងដៃគូអភិវឌ្ឍន៍ លោកទីប្រឹក្សាជំរឿនទាំងអស់ ព្រមទាំងសហការី និងមន្ត្រីរាជការដែលបានបំពេញការងារជំរឿន សូមប្រកបតែសុខភាពល្អ និងសម្រេចបានជោគជ័យគ្រប់ភារកិច្ច និងពុទ្ធពរទាំងប្រាំប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ!



Scanned with CamScanner